ទីស្តីការក្រសួងយុត្តិធម៌

លេខ ៩០០ ព្រទ.កយ-២០០២

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## __ជម្រាបមក__

## លោកស្រី ប្រធានតុលាការខេត្តព្រៃវែង

**__កម្មវត្ថុ:__** អំពីស្មារតីនៃអង្គប្រជុំ ស្តីពីការផ្សព្វផ្សាយលទ្ធផលការងារ និងសេចក្តីសម្រេចនៃមហាសន្និបាតរបស់ក្រសួងយុត្តិធម៌ ២០០២ របស់តុលាការខេត្តព្រៃវែងកាលពីថ្ងៃទី២២-០៥-២០០២ ។

**__យោង:__** លិខិតលេខ ១០ រប ២០០២ ចុះថ្ងៃទី២៨-០៥-២០០២ របស់តុលាការខេត្តព្រៃវែង ។

ខ្ញុំសូមជម្រាបលោកស្រីប្រធានក្រសួងយុត្តិធម៌បានទទួលរួចហើយនូវលិខិតរបស់លោក ដូចមានយោងខាងលើ ។ ក្រសួងមានការពេញចិត្តណាស់ចំពោះស្មារតីនៃអង្គប្រជុំផ្សព្វផ្សាយច្បាប់ និងការពង្រឹងគុណភាពការងារក្នុងអង្គភាពតុលាការខេត្តព្រៃវែង ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២២-០៥-២០០២ កន្លងទៅនេះ ដើម្បីជួយឱ្យកិច្ចការនេះកាន់តែល្អប្រសើរឡើង ក្រសួងសូមទាញអារម្មណ៍លោកស្រីជ្រាបថា តាមគោលការណ៍ច្បាប់តុលាការគ្រប់ខេត្ត-ក្រុង មានភារកិច្ចអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗទៀត ដែលនៅមានអំណាចជាធរមាននិងតម្រូវឱ្យមាននីតិវិធីដោះស្រាយសំណុំរឿងក្តីដូចគ្នាទាំងអស់នៅទូទាំងប្រទេស ។ ចំពោះស្មារតីនៃអង្គប្រជុំដែលលោកស្រីបានលើកឡើងក្នុងលិខិតយោងខាងលើឃើញថាមានមតិខ្វែងគ្នាមិនទាន់បានយល់ស្របគ្នានៅឡើយ ។ មានមតិខ្លះមានលក្ខណៈសមស្របទៅនឹងគោលបញ្ញត្តិច្បាប់ ឯមតិខ្លះផ្ទុយពីគោលការណ៍ច្បាប់ ។

ហេតុដូច្នេះ ដើម្បីពង្រឹងគោលការណ៍នីត្យានុកូលភាពក្នុងការអនុវត្តច្បាប់ឱ្យមានការឯកភាពគ្នាក្រសួងសូមបំភ្លឺអំពីចំណុចខ្វែងមតិគ្នាដូចតទៅនេះ៖

១/-អំពីពាក្យ(ភ្លាម) ក្នុងមាត្រា១៥២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ តាមអង្គសន្និបាតការងារក្រសួងយុត្តិធម៌ឆ្នាំ២០០២ បានសចថាពាក្យ(ភ្លាម) គឺកំណត់យករយៈពេលមួយពេលធ្វើការដោយឥតគិតថ្ងៃឈប់សម្រាកបន្ទាប់ពីសវនាការប្រកាសសាលក្រម ។ បើបិទសវនាការហើយមិនទាន់អាចប្រកាសសាលក្រមបាន ក៏មិនទាន់ចាប់គិតដែរ គឺចាប់គិតពីពេលប្រកាសសាលក្រមអង្គសេចក្តី ។ រាល់ការបកស្រាយទាំងឡាយណាដែលមានរយៈពេលខុសពីរនេះមិនត្រឹមត្រូវទេ ។

២/-អំពីរូបមន្តដីកាឃុំខ្លួន-ដីកាចាប់ខ្លួន-ដីកាសម្រេចមិនឃុំខ្លួន អង្គសន្និបាតក្រសួងយុត្តិធម៌សម្រេចរក្សាទុករូបមន្តរបស់ក្រសួងទុកជាបានការ។ ការប្រើប្រាស់រូបមន្តទាំងនេះ មិនបាច់ធ្វើសេចក្តីសម្រេចមួយដោយមានចែងអំពីមូលហេតុជាមុនសិននោះទេ ប៉ុន្តែសូមលោកស្រីចាត់ឱ្យចៅក្រមស៊ើបអង្កេត ចែងអំពីមូលហាតុ សំអាងហេតុ ដែលលោកនឹងធ្វើការសម្រេចក្នុងកំណត់ហេតុយកចម្លើយតែម្តង(ធ្វើយ៉ាងនេះគឺយើងកាត់បន្ថយរូបមន្តដែលត្រូវប្រើប្រាស់កុំឱ្យច្រើនពេក) ហើយឱ្យចៅក្រមស៊ើបអង្កេតលើកយកមូលហាតុ និងសំអាងហេតុដែលនាំឱ្យលោកសម្រេចមកដាក់ត្រង់ផ្នែកយល់ឃើញក្នុងរូបមន្តដីកាដែលលោកត្រូវប្រើហើយ ធ្វើសេចក្តីសម្រេចក្នុងដីកានោះតែម្តង ។

៣/-អំពីរូបមន្តសម្រង់សេចក្តីជំនុំជម្រះក្នុងរឿងព្រហ្មទណ្ឌ រូបមន្តនេះគេប្រើប្រាស់បន្ទាប់ពីជំនុំជម្រះប្រកាសសាលក្រមសម្រេចដល់អង្គសេចក្តី តាមករណីខាងក្រោម៖

ក-ក្នុងករណីជាប់ចោទ ត្រូវឃុំខ្លួនតាមដីកាឃុំខ្លួនជាមុន ហើយត្រូវចៅក្រមសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារករណីនេះនៅពេលបញ្ចប់សវនាការ ចៅក្រមត្រូវចេញសម្រង់សេចក្តីជំនុំជម្រះជូនទៅពន្ធនាគារឱ្យបន្តឃុំខ្លួនជនជាប់

ចោទ សាលក្រមដែលទើបនឹងបញ្ចប់សវនាការនេះ មិនទាន់មានសុពលភាពយកទៅអនុវត្តបានទេ ព្រោះមិនទាន់ចូលជាស្ថាពរ ហើយដីកាឃុំខ្លួនពីមុនក៏អស់សុពលភាពត្រឹមពេលសវនាការនេះដែរ ។ ចាប់ពីពេលនេះទៅគេលែងចោទថាឃុំខ្លួនលើសកំណត់ច្បាប់ទៀតហើយ ហើយដើម្បីឱ្យពន្ធនាគារអាចបន្តឃុំខ្លួនពិរុទ្ធជនបានមានតែប្រើរូបមន្តសម្រង់សេចក្តីជំនុំជម្រះទំរាំសាលក្រមចូលជាស្ថាពរ ទើបយើងចេញសម្រង់ឱ្យអនុវត្តទោស ។

ខ-ក្នុងករណីជនជាប់ចោទត្រូវឃុំខ្លួនតាមដីកាឃុំខ្លួនជាមុន ហើយត្រូវចៅក្រមសម្រេចឱ្យរួចផុតពីបទចោទ ករណីនេះ ចៅក្រមមិនទាន់ចេញសម្រង់សេចក្តីជំនុំជម្រះភ្លាមទេ រង់ចាំឱ្យផុតរយៈពេលប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាសិនបើព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ ចៅក្រមត្រូវចេញសម្រង់សេចក្តីជំនុំជម្រះនេះជូនទៅពន្ធនាគារដោយចុះនិទ្ទេសថាសំណុំរឿងនេះលោកព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ជនជាប់ចោទត្រូវបន្តឃុំខ្លួនរង់ចាំស្តាប់សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ បើលោកព្រះរាជអាជ្ញាមិនប្តឹងឧទ្ធរណ៍ទេ ចៅក្រមមិនត្រូវប្រើរូបមន្តសម្រង់សេចក្តីជំនុំជម្រះនេះទៅឱ្យពន្ធនាគារឱ្យដោះលែងទេ គឺត្រូវប្រើរូបមន្តដីកាដោះលែង ។

គ-ក្នុងករណីជនជាប់ចោទនៅក្រៅឃុំ ក្នុងករណីនេះចៅក្រមមិនចាំបាច់ប្រើប្រាស់រូបមន្តសម្រង់សេចក្តីជំនុំជម្រះរង់ចាំសាលក្រមចូលស្ថាព ទើបចេញសម្រង់សាលក្រមនេះបង្គាប់ឱ្យយកទៅអនុវត្តតែម្តង ។

សម្រង់សេចក្តីជំនុំជម្រះនេះ មិនអាចយកទៅប្រើប្រាស់ក្នុងការសុំបន្ធូរបន្ថយទោស ឬលើកលែងទោសដូចតុលាការមួយចំនួនបានអនុវត្តកន្លងមកបានឡើយ ហើយក្រឡាបញ្ជី ដែលមានសមត្ថកិច្ចចុះហត្ថលេខាលើសម្រង់សេចក្តីជំនុំជម្រះនេះគឺក្រឡាបញ្ជីសវនាការ ។

ហេតុដូច្នេះ សូមលោកស្រីប្រធាន ផ្សព្វផ្សាយឱ្យមន្ត្រីតុលាការក្រោមឱវាទបានជ្រាប និងអនុវត្តឱ្យបានឯកភាពគ្នាតាមការគួរ ។

សូមលោកស្រី ទទួលនូវសេចក្តីរាប់អានដ៏ស្មោះអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០២

**រដ្ឋមន្ត្រី**

<u>ចម្លងជូន</u>

-តុលាការគ្រប់ខេត្ត-ក្រុង

-ដើម្បីអនុវត្ត

**នាង ស៊ីផុន**